# របាយការណ៍ប្រចាំខែកក្កដា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែកក្កដា ឆ្នាំ ២០១៥ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ច សម្រេចលទ្ធផលដូចខាងក្រោម÷

1. <u>ស្ថានភាពមន្ត្រីរាជការ</u>÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣០ នាក់ ស្រ្តី ០៤ នាក់ និង ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. <u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>÷

- ចូលរួមវេទិកាសារធាណៈចំនួន ០៥ ដង
- ចូលរួមប្រជុំបើកសំណើដេញថ្លៃ ០៣ ដង
- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យ (JTWG-ED) ថ្ងៃទី ២៩/០៦/២០១៥ នៅសាលប្រជុំ មន្ទីរអប់រំយុវជន និងកីឡា
- ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់វិញ្ញាបនបត្របញ្ជាក់ការសិក្សា ជូនមន្ត្រី នៅថ្ងៃទី ២៩/០៦/២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមប្រជុំពិភាក្សា ស្តីពី ការត្រួតពិនិត្យការប្រើប្រាស់ដី និងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី សម្បទានសង្គមកិច្ច ថ្ងៃទី ២៦/០៦/២០១៥ នៅសាលប្រជុំ ផ.អ.៣
- ចូលរួមប្រជុំពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងផែនការ ឆ្នាំ ២០១៥-២០១៩ ថ្ងៃទី ២០/០៧/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិភាក្សា ស្តីពី ការរៀបចំផែនការថវិកា ឆ្នាំ ២០១៦ ថ្ងៃទី ០២/០៧/២០១៥ នៅក្រសួង អភិវឌ្ឍន៍ជនបទ
- ចូលរួមកិច្ចប្រជុំណែនាំ ស្តីពី ការរៀបចំសំណើគម្រោងវិនិយោគ បីឆ្នាំរំកិល ២០១៥-២០១៧ នៅថ្ងៃទី ០៣/០៧/២០១៥ នៅសាលប្រជុំមន្ទីរផែនការ
- ចូលរួមប្រជុំពិភាក្សាអំពីការបំពេញការងាររបស់មន្ត្រីរាជការ ថ្ងៃទី ០៣/០៧/២០១៥ នៅក្រសួងអភិវឌ្ឍន៍ ជនបទ
- ចូលរួមប្រជុំគណៈរដ្ឋមន្ត្រី (Video Conference) ថ្ងៃទី ១០/០៧/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមពិធីរុក្ខទិវាថ្នាក់ខេត្ត ថ្ងៃទី១៣/០៧/២០១៥ នៅឃុំឃ្សឹម ស្រុកស្នួល
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារលើគ្រប់វិស័យប្រចាំឆមាសទី១ ថ្ងៃទី ១៣/០៧/២០១៥ នៅសាល ក្រុមប្រឹក្សាខេត្ត ។

3. <u>សកម្មភាពតាមការិយាល័យ</u>÷

3.1. <u>ការិយាល័យរដ្ឋបាល និងបុគ្គលិក</u>÷

ក. <u>ផ្នែកការងារលិខិតចូល</u>÷ សរុបចំនួន ៥៣ លេខ ក្នុងនោះមាន:

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០១ លេខ
- លិខិតរបស់ក្រសួងសាមី ចំនួន ០៧ លេខ
- លិខិតក្រសួងនានា ចំនួន ០៨ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៣៧ លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ២៧ លេខ ក្នុងនោះមានៈ

- លិខិតទៅនាយកដ្ឋាន និងក្រសួង ចំនួន ០៣ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ២៤ លេខ

គ. <u>ផ្នែកការងារលិខិតបញ្ជាបេសកកម្ម</u>÷ សរុបចំនួន ១៤ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកកម្មលោកប្រធានមន្ទីរ ពី **ឯកឧត្តមអភិបាលខេត្ត** ចំនួន ០២ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រី ចំនួន ១២ លេខ

ឃ. <u>ផ្នែកបញ្ជីវត្តមាន</u>÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. **<u>ការិយាល័យផ្លូវជនបទ</u>**÷

***<u>សកម្មភាពការងារ</u>***

- ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ក្នុងស្រុកចិត្របុរី 0៦ ខ្សែ ប្រវែង ៨៣,២០០ ម៉ែត្រ ស្ថិតនៅឃុំគោលាប់ ឃុំសំបុក ឃុំចង្រ្កង់ ឃុំដារ ឃុំកន្ទួត និងឃុំថ្មអណ្ដើក
- ក្រុមការងារអន្តរក្រសួងរួមមានតំណាងក្រសួងអភិវឌ្ឍន៍ជនបទ និងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានចុះត្រួតពិនិត្យស្ថានភាពជាក់ស្ដែងនៃការខូចខាតរបស់ផ្លូវចំនួន ០១ ខ្សែ មានប្រវែង ២,៧០០ ម ស្ថិតនៅភូមិបុស្សទឹក ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ
- ចុះពិនិត្យស្ថានភាពទឹកជំនន់តាមព្រែកឆ្លូង ដែលបាននាំសម្រាស់ឫស្សី មកជាប់នឹងសរសរគ្រឹះស្ពានកំពង់ស្រែ ឃុំឆ្លូង ស្រុកឆ្លូង
- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈប្រចាំ ផ្លូវស្រែទ្រៀក-វាលកន្សែង ប្រវែង ៦,៣០០ ម៉ែត្រ ស្ថិតនៅឃុំដំរីផុង ស្រុកឆ្លូង និងផ្លូវរលៀក-ប្រម៉ា ប្រវែង ១០,៨០០ ម៉ែត្រ ស្ថិតនៅ ឃុំកំពង់ដំរី ស្រុកឆ្លូង
- ចុះពិនិត្យការងារជួសជុលបន្ទាន់ផ្លូវ បុស្សទឹក-ព្រែកប្រាំង ២,៧០០ ម៉ែត្រ ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ
- ចុះពិនិត្យការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប ផ្លូវសំរ៉ង-ចឹង ប្រវែង ៨,០០០ ម៉ែត្រ ស្ថិតនៅឃុំឃ្សឹម ស្រុកស្នួល និងផ្លូវក្បាលស្នួល-ស្នួលកើត ប្រវែង ៤,០០០ ម៉ែត្រ ស្ថិតនៅ ឃុំស្នួល ស្រុកស្នួល ។

**លទ្ធផលការងារ**

- ជួសជុលថែទាំជាលក្ខណៈប្រចាំ ផ្លូវស្រែទៀក-វាលកន្សែង ប្រវែង ៦,៣០០ ម៉ែត្រ ស្ថិតនៅឃុំដំរីផុង ស្រុកឆ្លូង និងផ្លូវរលៀក-ប្រម៉ា ប្រវែង ១០,៨០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង លទ្ធផលសម្រេចបាន ៧០%
- ជួសជុលបន្ទាន់ផ្លូវ បុស្សទឹក-ព្រែកប្រាំង ២,៧០០ ម៉ែត្រ ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ លទ្ធផលសម្រេចបាន ៦០%
- ជួសជុលផ្លូវថែទាំជាលក្ខណៈខួប ផ្លូវសំរ៉ង-ចឹង ប្រវែង ៨,០០០ ម៉ែត្រ ស្ថិត នៅឃុំឃ្សឹម ស្រុកស្នួល លទ្ធផលសម្រេចបាន ៤០% ។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ**÷

- ជួសជុលអណ្តូងស្នប់បានចំនួន ១៧ អណ្តូង ក្នុងស្រុកសំបូរ
  - ឃុំស្រែជិះ ១៣ អណ្តូង
  - ឃុំរលួស ០៤ អណ្តូង ។

3.4. **ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**÷ (គ្មានសកម្មភាព)

3.5. **ការិយាល័យអភិវឌ្ឍន៍សហគមន៍**÷

- ចុះបង្កើត គ.អ.ភ នៅភូមិសម្បទានកាំពី ឃុំសំបុក ស្រុកចិត្របុរី មានអ្នកចូលរួម ១១ នាក់ ស្រី ០៦ នាក់ ។

3.6. **ការិយាល័យជនជាតិដើមភាគតិច**÷

- ចូលរួមសហការណ៍ជាមួយមន្ទីររៀបចំដែនដីនគររូបនីយកម្ម និងសំណង់ នៅសហគមន៍ជនជាតិដើមភាគតិច គឺឃុំស្រែជិះ និងឃុំរលួសមានជ័យ ស្រុកសំបូរ ។

3.7. **ការិយាល័យថែទាំសុខភាពជនបទ**÷ (គ្មានសកម្មភាព)

3.8. **ការងារបណ្តុះបណ្តាលមន្ត្រីរាជការ**÷

- លោក ឈិត សុភា ប្រធានការិយាល័យសេដ្ឋកិច្ចជនបទ បានចូលរួមសិក្ខាសាលាបង្ហាញសមិទ្ធិផលកម្មវិធីថ្នាក់តំបន់ កាលពីថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៥ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន ក្រោមការឧបត្ថម្ភដោយអង្គការសេដ្ឋកិច្ចជនបទ PVD ។
- ម៉ក់ ម៉ាលីតា (ស្រី) មន្ត្រីការិយាល័យផែនការ និងស្ថិតិ បានចូលរួមសិក្ខាសាលាស្តីពីការប្រើប្រាស់ឯកសារព័ត៌មាន កាលពីថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១៥ នៅសាលប្រជុំ UNDP ខេត្តកំពង់ចាម ក្រោមការឧបត្ថម្ភដោយ UNDP ។

- លោក ឈិត សុភា បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី ការចាប់ផ្តើមគម្រោងសាកវប្បកម្មកម្ពុជា ដើម្បីរកប្រាក់ចំណូល និងអាហាររូបត្ថម្ភ កាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៥ នៅសណ្ឋាគារ ហ៊ា ប៊ុន្នី ក្រោមការឧបត្ថម្ភដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

4. <u>ទិសដៅបន្ត</u>÷

- ចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ស្រុកស្នួលដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ និងផែនទីក្នុងខេត្តក្រចេះ
- ចុះជួសជុលថែទាំជាលក្ខណៈប្រចាំ ផ្លូវស្រែទ្រៀក-វាលកន្សែង ប្រវែង ៦,៣០០ ម៉ែត្រ នៅឃុំដំរីផុង ស្រុកឆ្លូង និងផ្លូវរលៀក-ប្រម៉ា ប្រវែង ១០,៨០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង
- ចុះជួសជុលផ្លូវថែទាំជាលក្ខណៈខួប ផ្លូវសំរ៉ង-ចឹង ប្រវែង ៨,០០០ ម៉ែត្រ ស្ថិតនៅឃុំរ្សីម ស្រុកស្នួល និងផ្លូវក្បាលស្នួល-ស្នួលលិចប្រវែង ៤,០០០ ម៉ែត្រ ឃុំស្នួល ស្រុកស្នួល
- ចុះជួសជុលផ្លូវខ្សាត់-ស្ទឹងទ្រ ប្រវែង ៦,៨០០ ម៉ែត្រ ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ
- បន្តចុះពិនិត្យការងារជួសជុលអណ្តូងនៅស្រុកចិត្របុរី
- ចុះសិក្សាពីតម្រូវការរបស់ប្រជាពលរដ្ឋ ដែលត្រូវការពូជក្រូចថ្លុងផ្អែម ចំនួន ៨០ គ្រួសារ នៅភូមិសម្បទានកាកុត ឃុំសំបុក ស្រុកចិត្របុរី ។

**ប្រធានមន្ទីរ**